ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

APHR

# សមាជិកសភាអាស៊ាន ទាមទារឲ្យមានការដោះលែង អ្នកការពារសិទ្ធិមនុស្សនៅប្រទេសកម្ពុជា

ទីក្រុងចាកាតា ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ - នៅថ្ងៃនេះ សមាជិកសភាមកពីតំបន់អាស៊ីអាគ្នេយ៍ ទាមទារឲ្យមានការដោះលែងជាបន្ទាន់ និងឥតលក្ខខណ្ឌនូវអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាចំនួនប្រាំរូប ដែលកំពុងជាប់ឃុំ និងត្រូវបានចោទប្រកាន់។

ដោយមានការចូលរួមពីបណ្ដាអង្គការសង្គមស៊ីវិល ទាំងថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ច្រើនជាង៥០អង្គការ ដើម្បីជម្រុញជាថ្មីឲ្យមានការធានានូវសេរីភាពរបស់អ្នកទាំងប្រាំរូប អង្គការសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស ថ្កោលទោសចំពោះការបន្តឃុំខ្លួនអគ្គលេខាធិការរងមួយរូបនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងមន្ត្រីបួនរូបនៃសមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ដែលជាក្រុមការពារសិទ្ធិមនុស្សមួយដ៏សំខាន់ ក្រោមបទចោទប្រកាន់ដែលមានលក្ខណៈប្រឌិត។ សមាជិកសភាមកពីតំបន់អាស៊ីអាគ្នេយ៍ ទាមទារឲ្យបញ្ឈប់ការយាយីតាមផ្លូវតុលាការចំពោះអ្នកទាំងប្រាំរូប និងអំពាវនាវដល់សហគមន៍អន្តរជាតិចូលរួមជម្រុញឲ្យមានការដោះលែងអ្នកការពារសិទ្ធិមនុស្សទាំងប្រាំរូបនៅកម្ពុជា ដែលត្រូវបានឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលជាង ១០០ថ្ងៃមកហើយ។

ប្រធានអង្គការសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស ឯកឧត្តម Charles Santiago ដែលជាសមាជិកសភាម៉ាឡេស៊ី បានថ្លែងថា "យើងមានភាពច្បាស់លាស់ ដោយមិនមានមន្ទិលសង្ស័យអ្វីឡើយ ក្នុងការគាំទ្រឲ្យមានការដោះលែងអ្នកការពារសិទ្ធិមនុស្សទាំងប្រាំរូបនៅកម្ពុជានេះ។ គ្មាននរណាម្នាក់អាចត្រូវបានចាប់ខ្លួន ឬឃុំខ្លួន ដោយរំលោភបំពាន និងតាមអំពើចិត្តនោះឡើយ ហើយសមាជិកអង្គការសង្គមស៊ីវិលមិនត្រូវស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ ក្នុងការបំពេញការងាររបស់ពួកគេនោះទេ។"

ឯកឧត្តមបានបន្តទៀតថា "បទចោទប្រកាន់លើករណីនេះ ត្រូវបានមើលឃើញយ៉ាងច្បាស់ថាធ្វើឡើងដោយហេតុផលនយោបាយ និងបានធ្វើឲ្យនីតិរដ្ឋនៅកម្ពុជាដែលមានភាពទន់ខ្សោយរួចទៅហើយនោះ កាន់តែចុះអន់ខ្សោយថែមទៀត។ អាជ្ញាធរកម្ពុជាចាំបាច់ត្រូវដោះលែងអ្នកការពារសិទ្ធិមនុស្សទាំងប្រាំរូបនេះ ប្រសិនបើពួកគេចង់មានឱកាសទទួលបានជំនឿទុកចិត្តពីអន្តរជាតិវិញ។"

មន្ត្រីបួនរូបនៃសមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា រួមមាន លោក **នី សុខា** លោក **យី សុខសាន្ត** លោក **ណៃ វង់ដា** និងលោកស្រី **លឹម មុន្នី** ត្រូវបានចាប់ខ្លួនកាលថ្ងៃទី០៨ ខែមេសា ជាមួយគ្នានឹងលោក **នី ចរិយា** អគ្គលេខាធិការរង គ.ជ.ប ហើយអ្នកទាំងប្រាំរូបត្រូវបានចោទប្រកាន់ពីបទសូកប៉ាន់សាក្សី នៅក្នុងដំណើរការក្ដីលើបណ្ដឹងប្រឆាំងលោក **កឹម សុខា** អនុប្រធានគណបក្សជំទាស់។ សំណើសុំតម្កល់ប្រាក់ដើម្បីនៅក្រៅឃុំបណ្ដោះអាសន្នរបស់អ្នកទាំងប្រាំ

រូបត្រូវបានសាលាឧទ្ធរណ៍បដិសេធ កាលពីថ្ងៃទី១៣ ខែមិថុនា កន្លងទៅ ហើយអ្នកទាំងប្រាំរូបប្រឈម នឹងការជាប់ពន្ធនាគាររហូតដល់ ១០ឆ្នាំ ប្រសិនបើត្រូវបានរកឃើញទោសកំហុស។

ឯកឧត្តម Santiago មានប្រសាសន៍ថា "អាជ្ញាធរកម្ពុជាកំពុងធ្វើឲ្យមានការចំអកចំពោះប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ដោយសារការបន្តចំណាត់ការប្រឆាំងនឹងអ្នកទាំងប្រាំរូប។ ការនាំខ្លួនមន្ត្រីអង្គការមិនមែនរដ្ឋាភិបាលមកកាត់ទោសតាមផ្លូវតុលាការ ដោយហេតុបានផ្តល់ជំនួយផ្នែកច្បាប់ដល់ប្រជាពលរដ្ឋម្នាក់ដែលកំពុងត្រូវការជំនួយផ្នែកច្បាប់នេះ គឺជារឿងអយុត្តិធម៌ដ៏ធ្ងន់ធ្ងរ ដែលស្ថានភាពដ៏អាក្រក់នេះបានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់ថា តុលាការកំពុងត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល ដើម្បីបម្រើរបៀបវារៈនយោបាយ។"

ការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សទាំងប្រាំរូបនេះ បានកើតឡើងនៅក្នុងបរិបទនយោបាយនៅកម្ពុជា ដែលមានភាពប្រទូសរ៉ាយកាន់តែកើនឡើងចំពោះសង្គមស៊ីវិល។ ក្នុងឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាត្រូវបានមើលឃើញថា មានការកើនឡើងនូវការធ្វើទុក្ខបុកម្នេញ ការបំភិតបំភ័យ និងការវាយប្រហារប្រឆាំងនឹងសម្លេងអ្នកជំទាស់ និងអ្នកឯករាជ្យ ព្រមទាំងកើនឡើងនូវចំនួនអ្នកទោសនយោបាយដែលត្រូវបានឃុំខ្លួន។ ឃាតកម្មលើលោកបណ្ឌិត **កែម ឡី** អ្នកវិភាគនយោបាយកម្ពុជាដ៏សំខាន់មួយរូប កាលពីថ្ងៃទី១០ កក្កដា កន្លងទៅ បានបង្កឲ្យការព្រួយបារម្ភបន្ថែមទៀតចំពោះសុវត្ថិភាពរបស់ក្រុមអង្គការស៊ីវិល។

លោកជំទាវ Eva Kusuma Sundari សមាជិកសភាឥណ្ឌូនេស៊ី បានថ្លែងថា "យើងកំពុងឃ្លាំមើលចំពោះការរំលោភបំពានលើសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។ បញ្ហារំលោភបំពាននេះចាំបាច់ត្រូវបញ្ចប់។ អាជ្ញាធរមានកាតព្វកិច្ចដើម្បីធានាថា ក្រុមអង្គការសង្គមស៊ីវិល ព្រមទាំងអ្នករិះគន់រដ្ឋាភិបាលអាចមានសេរីភាពគ្រប់គ្រាន់ដើម្បីបំពេញការងារ និងបញ្ចេញមតិ ដោយមិនមានការគម្រាមកំហែង និងការធ្វើទុក្ខបុកម្នេញផ្សេងៗ"។

លោកជំទាវ **មូរ សុខហួរ** សមាជិកសភាកម្ពុជា បានថ្លែងថា "ជូនចំពោះអ្នកការពារសិទ្ធិមនុស្សទាំងប្រាំរូប ដែលកំពុងជាប់ឃុំនៅពន្ធនាគារ ដោយត្រូវបានរំលោភបំពានលើសិទ្ធិចម្បងផ្សេងៗះ ត្រូវដឹងថា យើងមិនដែលបំភ្លេចអ្នកទាំងអស់គ្នានោះទេ ហើយយើងនៅតែឈរជាមួយអ្នកទាំងអស់គ្នាដោយសាមគ្គីភាព។ យើងនឹងបន្តទាមទារឲ្យមានការដោះលែងអ្នកទាំងអស់គ្នា ហើយនឹងជម្រុញដំណើរឆ្ពោះទៅរកអនាគតមួយសម្រាប់ប្រទេសកម្ពុជា ដែលមានការគោរពសិទ្ធិមនុស្ស និងការគោរពឆន្ទៈរបស់ប្រជាពលរដ្ឋកម្ពុជា។"